ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# របាយការណ៍
# ស្តីពី
# វេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី២ ឆ្នាំ២០១៨

គណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានសហការជាមួយអង្គការការីតាសកម្ពុជា រៀបចំធ្វើកម្មវិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប **ក្រោមអធិបតីយភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅរាជធានីភ្នំពេញ (មជ្ឈមណ្ឌល និងពិព័រណ៍កោះពេជ្រ អគារ KL) វេលាម៉ោង ១៦.00នាទីរសៀល នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ។

**សមាសភាព ចូលរួមមាន ៖**

- **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី នន្ទ ងែត សម្តេចព្រះមហាសង្ឃរាជ** នៃព្រះរាជាណាចក្រកម្ពុជា។
- **សម្តេចព្រះអភិសេរីសុគន្ធាមហាសង្ឃរាជាធិបតី ភិក្ខុឧត្តមសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ** នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា។
- **សម្តេចព្រះពុទ្ធជ័យមុនីធិបតី ឃឹម សន ព្រះប្រធានលេខាធិការដ្ឋាន គណៈសង្ឃនាយក** នៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះមេគណរាជធានីភ្នំពេញ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ។
- លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអនុប្រធានអចិន្ត្រៃ គ.ជ.ប.ជ និងឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គលេខាធិការរង និងមន្ត្រីលេខាធិការដ្ឋានគ្រប់លំដាប់ថ្នាក់នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ។
- ឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌
- លោកជំទាវ វេជ្ជបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួងស្ថាប័នរដ្ឋាភិបាល គណៈដឹកនាំជាន់ខ្ពស់នៃឥស្លាមសាសនា អភិបាលតំណាងបរិស័ទកាតូលិក ព្រឹទ្ធាចារ្យ តំណាងគ្រិស្តបរិស័ទបំណងល្អ ព្រមទាំងតាជី យាយជី មន្ត្រីរាជការ សម្ព័ន្ធយុវជន យុវនារី អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ បរិស័ទ និងសាសនិកគ្រប់និកាយទាំងអស់។

សរុបរួមចំនួនប្រមាណ១៥00អង្គ/នាក់ (ប្រុស&ស្រី) ។

❖ ជាកិច្ចចាប់ផ្តើមកម្មវិធី **ឯកឧត្តម ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា បានឡើងសន្ទរកថាស្វាគមន៍ជូនអង្គពិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា៖

វេទិកាអន្តរសាសនានេះ គឺជាគំនិតផ្តួចផ្តើមរៀបចំឡើងដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងធម្មការ និងសាសនា ថ្នាក់ដឹកនាំសាសនាទាំងអស់ រួមមានព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រីស្ទសាសនា ដែលមានកាតូលិក គ្រីស្ទបរិស័ទដំណឹងល្អ អង្គការការីតាសកម្ពុជា និងអង្គការដៃគូមួយចំនួនទៀត។ វេទិកាអន្តរសាសនាលើកទី២នេះ ជាពិធីសូត្រធម៌ អធិដ្ឋាន បួងសួង និងបញ្ជូនសារ ដើម្បីរួមចំណែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់ទម្រង់រូបភាព និងបញ្ចប់ទេសភាពសម័យទំនើប។

បើទោះបីជាមានការខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល និងស្ថាប័នដៃគូពាក់ព័ន្ធនានានៅលើសកលលោកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏បញ្ហានេះនៅតែបន្តកើតមានឡើងជាច្រើនក្នុងទម្រង់ផ្សេងៗគ្នាដូចជា៖ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម បញ្ហាផ្លូវភេទ និងសេរីរាង្គជាដើម ។ តាមរបាយការណ៍របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថា មានបុរស ស្ត្រី និងកុមាររាប់លាននាក់បាននឹងកំពុងរងគ្រោះដោយសារអំពើជួញដូរទាំងនោះ។

ដើម្បីរួមចំណែកបន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស វេទិកាអន្តរសាសនាលើកទី២នេះ គឺរៀបចំឡើងក្នុងគោលបំណងសំខាន់ៗចំនួន៣គឺ៖

*១-ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹងនៃ អំពើជួញដូរមនុស្ស និងតួនាទីសំខាន់ៗរបស់ថ្នាក់ដឹកនាំសាសនាទាំងឡាយ ក្នុងការអប់រំប្រជាជន ក្នុងការការពារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស និងលុបបំបាត់ទាសភាពសម័យទំនើប។*

*២-ដើម្បីពង្រីក និងពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងស្ថាប័នពាក់ព័ន្ធ ពិសេសស្ថាប័នសាសនា ក្នុងការងារអប់រំផ្សព្វផ្សាយអំពើជួញដូរមនុស្សនៅតាមវត្តអារាម ព្រះវិហារ និងតាមពិធីសាសនានានា។*

*៣-ដើម្បីការឲ្យសម្លេងសូត្រធម៌ អធិដ្ឋាននេះ ផ្តល់នូវក្តីសង្ឃឹមដល់ជនរងគ្រោះ រងទុក្ខវេទនាដោយសារអំពើជួញដូរមនុស្ស និងសូមឲ្យពួកគាត់ឆាប់បានទទួលនូវសេរីភាពឡើងវិញ។*

វេទិកាអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺមិនត្រឹមតែជាវេទិកាគំរូថ្នាក់ជាតិមួយប៉ុណ្ណោះទេ គឺសម្រាប់ថ្នាក់តំបន់ និងពិភពលោកទាំងមូល ។ វេទិកានេះជាសក្ខីភាពមួយបង្ហាញអំពីភាពសុខដុមរមនានៃសាសនាទាំងឡាយនៅព្រះរាជាណាចក្រកម្ពុជា ។ មិនតែប៉ុណ្ណោះ វេទិកានេះបញ្ជាក់ពីការប្តេជ្ញាចិត្ត និងការចាប់ផ្តើមអនុវត្តន៍រួមគ្នាមួយរវាងសានាធំៗទាំងអស់ លើទស្សនៈវិស័យតែមួយគឺប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់មនុស្ស ការកសាងសន្តិភាព និងសុខដុមរមនារបស់មនុស្ស ក្នុងសង្គមជាតិកម្ពុជាទាំងមូល។

❖ បន្ទាប់មកលោក **គឹម រតនា** នាយកប្រតិបត្តិអង្គការការីតាសកម្ពុជា តំណាងឲ្យគណៈកម្មការរៀបចំ និងគណៈកម្មការអនុតំបន់ទន្លេមេគង្គដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមាន៖(ការីតាសកម្ពុជា ភូមិមា ថៃ វៀតណាម និង ម៉ាកាវ) ឡើងថ្លែងចំណាប់អារម្មក្នុងអង្គពិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជានេះថា៖

អំពើជួញដូរមនុស្សនៅតែកំពុងកើតមានគ្រប់ប្រទេសលើសកលលោក ក្នុងទម្រង់ និងរូបភាពផ្សេងៗគ្នាជាច្រើនដូចជា៖ ការកេងប្រវ័ញ្ចពលកម្ម ការកេងប្រវ័ញ្ចផ្លូវភេទ និងសរីរាង្គ។ល។ តាមរបាយការណ៍របស់អង្គការសហប្រជាជាតិ និងរបាយការណ៍ Global slavery Index មានបុរស ស្ត្រី និងកុមាររាប់លាននាក់លើសកលលោក ជាពិសេស

ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក រួមទាំងកម្ពុជាផងដែរ បានក្លាយជាជនរងគ្រោះ យ៉ាងអនោចអធម្មដោយសារអំពើទាសភាពទាំងនេះ ។

ទោះបីយើងមានការខិតខំប្រឹងប្រែង ការសម្រេចបាននូវលទ្ធផលជាច្រើនឥតគណនាពីសំណាក់រាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិនានាក៏ពិតមែន ទាំងការបង្ការ បង្ក្រាប និងដាក់ទោសទាន់ដល់ជនល្មើសយ៉ាងណាក៏ដោយអំពើជួញដូរមនុស្ស និងទាសភាពបែបទំនើបនេះនៅមិនទាន់មានភាពល្អប្រសើរនៅឡើយ ទាំងពិភពលោក ទាំងក្នុង តំបន់ ក៏ដូចជាក្នុងព្រះរាជាណាចក្រកម្ពុជាយើងផងដែរ។ ដូច្នេះកិច្ចការនេះទាមទារឲ្យយើងមានការប្តេជ្ញាចិត្ត និងការចូលរួមបន្ថែមទៀតពីសំណាក់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសការចូលរួមរបស់សាសនានានាដ៏សំខាន់នេះ។

លើសពីការខិតខំប្រឹងប្រែង និងលើសពីសមត្ថភាពដែលមនុស្សអាចធ្វើបាននោះ យើងសង្ឃឹមថា តាមរយៈការសូត្រធម៌ អធិដ្ឋាន បួងសួងតាមជំនឿសាសនានីមួយៗ សុំពរពីព្រះជាម្ចាស់ ដើម្បីឲ្យយើងប្រកបដោយកម្លាំងកាយចិត្ត និងប្រាជ្ញាញាណ និងសេចក្តីក្លាហានក្នុងការបំពេញភារកិច្ចដ៏លំបាកនេះបន្តទៀត។ និងសុំពរពីព្រះជាម្ចាស់ដ៏មានតេជានុភាពសព្វប្រកា ជួយបំភ្លឺ និងបន្ទន់ចិត្តមនុស្សឲ្យស្គាល់បុណ្យបាប ស្គាល់ល្អ និងអាក្រក់។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានហៅ "ការជួញដូរមនុស្សជាអំពើបាប អំពើអក្រក់ថោកទាបគួរឲ្យអាម៉ាសបំផុត និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងសាហាវព្រៃផ្សៃ"។ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើបមិនគ្រាន់តែជាប្រធានបទសម្រាប់ពិភពលោក ឬរដ្ឋាភិបាលប៉ុណ្ណោះទេ គឺជាបញ្ហារបស់យើងទាំងអស់គ្នា ដូច្នេះយើងត្រូវតែរួបរួមគ្នាដើម្បីលើកកម្ពស់ផ្សព្វផ្សាយការយល់ដឹង បង្ការ ទប់ស្កាត់ បញ្ឈប់ឲ្យបាននូវទាសភាពសម័យទំនើបនេះ ព្រមទាំងយកចិត្តទុកដាក់ការការពារថែរក្សាជនរងគ្រោះដែលជាបងប្អូនប្រុស ស្រី និងកុមាររបស់យើង ឲ្យគាត់រស់នៅក្នុងក្តីសង្ឃឹម និងសេចក្តីថ្លៃថ្នូរ។

❖ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានឡើងមានមតិស្វាគមន៍ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់ **សម្តេចព្រះអគ្គមហាសេនាបតីតេជោ គ្រប់ព្រះអង្គ** សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **និងជាប្រធានគណៈកម្មាធិការជាតិ** គ.ជ.ប.ជ បានធ្វើបទបង្ហាញតាមរយៈរបាយការណ៍ ស្តីពីស្ថានភាពជួញដូរមនុស្ស ជូនអង្គពិធីទាំងមូល ដែលមានខ្លឹមសារដូចតទៅៈ

បច្ចុប្បន្ននេះ បញ្ហាជួញដូរមនុស្សនៅតែជាប្រធានបទដ៏ក្តៅគគុក ដែលប្រទេសនានាលើពិភពលោក បាននិងកំពុងតែយកចិត្តទុកដាក់ ដោះស្រាយ ប្រយុទ្ធប្រឆាំង និងលុបបំបាត់យ៉ាងសកម្ម។ តាមរបាយការណ៍ពីអង្គការសហប្រជាជាតិ គ្រាន់តែនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មានជនរងគ្រោះដែលជាបុរស ស្ត្រី យុវវ័យ កុមារ និងទារកប្រមាណជិត១២លាននាក់ ដែលកំពុងតែទទួលរងនូវការរំលោភបំពាន បំបាត់សិទ្ធិជាមនុស្ស និងត្រូវគេកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរក្នុងរូបភាពជាទាសភាពក្នុងសម័យទំនើប ។

មនុស្សទាំងនោះត្រូវបានគេលួងលោម ឆបោក ទាក់ទាញដោយការសន្យា ឬការបង្ខិតបង្ខំ ដើម្បីបានចាកចេញពីសំណាញ់សុវត្ថិភាព រួចជួបនឹងភាពទ័លច្រក ដែលជាអន្ទាក់នៃការជួញដូរមនុស្ស ការបង្ខិតបង្ខំឲ្យបម្រើសេវាភេទ ឬឲ្យធ្វើការធ្ងន់ធ្ងរ ក្នុងស្ថានភាពគ្រោះថ្នាក់ ឬត្រូវបានឃុំឃាំងខ្លួន មិនឲ្យមានទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅដើម្បីរំលោភបំពាន ធ្វើទារុណកម្ម បង្ខំឲ្យប្រើគ្រឿងញៀនពង្វក់ស្មារតី បង្ខំឲ្យសុំទាន ឬដកហូតសរីរាង្គ ឬលក់ដូរបន្តទៅតំបន់ផ្សេងទៀត។ ជនទាំងនោះ ត្រូវបានគេកេងប្រវ័ញ្ច យកផលចំណេញ ពីកម្លាំងពលកម្ម ពីរូបរាងកាយ ខាតបង់

ពេលវេលា ធនធាន សុខភាព ដែលមួយចំនួនក្លាយជាជនជរាពិការបាត់បង់សមត្ថភាពពលកម្ម វិកលចរឹត ឬខ្លះបានបាត់បង់ជីវិត យ៉ាងអាណោចអាធម្ម ដែលមួយចំនួនធំ បាត់ដំណឹង មិនទាំងដឹងថា តើកំពុងតែនៅទីណាផង។

តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ហើយអំពើជួញដូរមនុស្ស មានជាតុផ្សំបីៈ

*១.សកម្មភាពៈ ដែលមានការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ការប្រគល់ ឬការទទួលយកមនុស្សដើម្បីដោះដូរជាផលប្រយោជន៍ ។*

*២.មធ្យោបាយ (វិធីសាស្ត្រ)ៈ រួមមាន ការលួងលោម ការគំរាមកំហែង ការប្រើកម្លាំងបាយ ឬទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការបោកបញ្ឆោត ការបំពានដោយអំណាច ការរំលោភលើភាពទន់ខ្សោយ ឬការផ្តល់ ឬទទួលយកតម្រៃឬអត្ថប្រយោជន៍ណាមួយដោះដូរនឹងការយល់ព្រមពីបុគ្គលណាម្នាក់ដែលមានអំណាចគ្រប់គ្រងលើបុគ្គលម្នាក់ទៀត ។*

*៣.គោលបំណងៈ ដើម្បីកេងប្រវ័ញ្ចផលប្រយោជន៍ដោយទុច្ចរឹត មានជាអាទិ៍ ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឬទម្រង់ ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ឬសេវាកម្ម ដោយបង្ខំតាមបែបទាសភាព ឬការអនុវត្តស្រដៀងគ្នា នឹងសេវាកម្មទាសភាព ឬការដកហូតយកសរីរាង្គជាដើម។*

លទ្ធផលចុងក្រោយគឺជនរងគ្រោះ អាចក្លាយជាៈ

- ពេស្យាចារ
- អ្នកបម្រើតាមផ្ទះដែលត្រូវគេបង្ខំឬរំលោភបំពាន ឬកេងប្រវ័ញ្ច
- ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ធ្វើការងាររំលោះបំណុល
- អាពាហ៍ពិពាហ៍បែបទាសភាព ឬក្នុងគោលបំណងទុច្ចរិត
- សុំកូនក្លែងក្លាយឬសុំកូនក្នុងឆន្ទៈទុច្ចរិត
- បម្រើក្នុងសេវាកំសាន្ត ឬទេសចរណ៍ផ្លូវភេទ លើកុមារ
- ផលិត ចែកចាយ រូបភាពនិងសម្ភារអាសអាភាស
- អ្នកសុំទាន និងពលកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ គ្រោះថ្នាក់ និងកេងប្រវ័ញ្ច
- ត្រូវបានប្រើប្រាស់ លួងលោម ឬបង្ខិតបង្ខំ ក្នុងសកម្មភាពទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ
- ត្រូវបានបង្ខំ ឬបោកបញ្ឆោតឲ្យប្រើប្រាស់គ្រឿងញៀន ជាមធ្យោបាយដើម្បីធ្វើឱ្យក្លាយជាទាសករ
- ត្រូវបានដកហូតយកសរីរាង្គមួយ ឬច្រើន ដើម្បីធ្វើអាជីវកម្ម.....។ល។

អំពីស្ថានភាពនៃអំពើជួញដូរមនុស្ស ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាៈ

- អំពើជួញដូរមនុស្សមានច្រើនទម្រង់ និងបានបង្កប់នៅក្នុងរូបភាពជាច្រើន ក្នុងនោះមាន ការធ្វើទេសន្តរប្រវេសន៍ស្វែងរកការងារ ដោយប្រថុយប្រថាន ការស្វែងរកគូស្រករនៅក្រៅប្រទេស អំពើពពោះជំនួសជាដើម។
- ជារៀងរាល់ថ្ងៃ ប្រជាពលរដ្ឋ បានស្វែងរកគ្រប់មធ្យោបាយដើម្បីចាកចេញពីប្រទេស ដោយប្រថុយប្រថាន ឆ្លងកាត់ព្រំដែន ដោយមិនមានឯកសារត្រឹមត្រូវ ។ ជាទូទៅ ពលករទាំងនោះ ត្រូវប្រឈមនឹងការចាប់ឃាត់ខ្លួន ឬ

ទទួលរងគ្រោះថ្នាក់ ដោយការរត់គេចវេសពីសមត្ថកិច្ច នាំឲ្យរងគ្រោះថ្នាក់ចរាចរណ៍ ឬ ជាន់មីន ឬរងការបាញ់ប្រហារ ជាដើម ។

- ពលករនេសាទមួយចំនួន ត្រូវបានគេក្លែងឯកសារអត្តសញ្ញាណ ដើម្បីបញ្ជូនចេញទៅធ្វើការ នៅក្នុងសមុទ្រអន្តរជាតិ តាមបណ្តាប្រទេសផ្សេងៗ និងត្រូវបានឃាត់ខ្លួន និងបញ្ជូនត្រឡប់ជាបន្តបន្ទាប់ តែមានពេលខ្លះ បញ្ជូនខុសទិសដៅ ដោយសារតែអត្តសញ្ញាណមិនច្បាស់លាស់។ ប្រជាជនខ្លះ បានប្រថុយប្រថាននឹងការស៊ីឈ្នួលចូលកាប់ ឬជញ្ជូនឈើមានតម្លៃ នៅក្នុងទឹកដីថៃ ឬឡាវ ដែលពួកគាត់មិនបានដឹងពីច្បាប់ទម្លាប់ និងគ្រោះថ្នាក់ ហើយត្រូវបានអាជ្ញាធរប្រទេសជិតខាងចាប់ឃាត់ខ្លួន ឬដាក់ពន្ធនាគារ ឬទទួលគ្រោះថ្នាក់ជាដើម ។ ពលករជាច្រើន ត្រូវបានជាប់ក្នុងពន្ធនាគារ និងរងការចោទប្រកាន់អំពើបទល្មើសផ្សេងៗ ដែលមួយចំនួន មិនបានទំនាក់ទំនាក់មកគ្រួសារឲ្យបានដឹងឡើយ ។
- ចំពោះការងារនេសាទសមុទ្រ គឺប្រកបដោយគ្រោះថ្នាក់បំផុត និងមិនទាន់មានការធានា អំពីសុវត្ថិភាពតាមផ្លូវច្បាប់អំពីលក្ខណ្ឌការងារដ៏លំបាក និងប្រកបដោយគ្រោះថ្នាក់នៅឡើយ ។
- ពលករ ពលការិនីខ្លះ ត្រូវបានទទួលរងទារុណកម្មយ៉ាងធ្ងន់ធ្ងរពីនិយោជក រហូតមិនអាចទ្រាំទ្របាន ។
- ចំណែកនៅក្នុងប្រទេស ក៏មានកើតឡើងនូវអំពើកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារ ដែលជាបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ។ ថ្មីៗនេះ មានបញ្ហាថ្មី ដែលបានកើតឡើង គឺការជួលពរពោះជំនួស ដើម្បីនាំទារកចេញទៅក្រៅប្រទេស ដែលជាករណីពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស ជាពិសេសទារក ។ មិនតែប៉ុណ្ណោះ អំពើជួញដូរសរីរាង្គក៏បាន និងកំពុងតែកើតឡើងជាបន្តបន្ទាប់ ។
- ពីក្រៅប្រទេស ពលករមួយចំនួន បាននឹងកំពុងត្រូវបានបញ្ជូនត្រឡប់មកវិញ ព្រោះតែភាពខុសច្បាប់ ជាជនរងគ្រោះ និងជាសាកសព ។ នេះគឺជាសោកនាដកម្មដែលបង្កដោយអំពើជួញដូរមនុស្ស ដែលមិនត្រូវបណ្តែតបណ្តោយឲ្យកើតមានបន្តទៀតឡើយ ។

តែរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែង ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ដើម្បីប្រយុទ្ធប្រឆាំងនិងឈានទៅលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ។

❖ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានមានប្រសាសន៍ទាក់ទងនឹងព្រឹត្តិការណ៍ដ៏មហោឡារិក ដែលសាសនាធំៗទាំង៤ (១.ព្រះពុទ្ធសាសនា ទី២.ឥស្លាមសាសនា ទី៣.គ្រីស្ទបរិស័ទកាតូលិក និងទី៤. គ្រីស្ទបរិស័ទដំណឹងល្អ)បានរួមសហការគ្នាបានយ៉ាងល្អ ក្នុងនាមប្រមុខរាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលកើតឡើងជាបន្តបន្ទាប់គួរឲ្យព្រួយបារម្ភ ។ យោងតាមរបាយការណ៍របស់អង្គការសហប្រជាជាតិ និងរបាយការណ៍ Global slavery Index មានបុរស ស្ត្រី យុវវ័យ និងកុមាររាប់លាននាក់លើសកលលោក ជាពិសេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក រួមទាំងកម្ពុជាផងដែរ បានក្លាយជាជនរងគ្រោះយ៉ាងអនោចអធម្មដោយសារអំពើទាសភាពទាំងនេះ ។

សម្តេចក្រឡាហោម បានមានប្រសាសន៍ទាក់ទងនឹងក្រសួងការបរទេសសហរដ្ឋអាមេរិកបានផ្តល់ចំណាត់ថ្នាក់លេខ២ជូនដល់ប្រទេសកម្ពុជាយើង សម្រាប់ការជួញដូរមនុស្សនៅលើសកលលោក ខណៈដែលរាជរដ្ឋាភិបាលមានឆន្ទៈយ៉ាងពិតប្រាកដ ដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបឲ្យបានទាំងស្រុង។ ហើយតាមការវាយតម្លៃនេះ យើងមិនធ្លាប់ធ្លាក់ដល់លេខ៣នោះទេ ឥឡូវយើងបានឈរលើចំណាត់ថ្នាក់លេខ២ជាប់ៗគ្នា គឺពីរ បីឆ្នាំចុងក្រោយនេះ ដែលជាមោទនភាពរបស់យើងផងដែរ ប្រហែលជាមកពីមានការខិតខំប្រឹងប្រែង ប៉ុន្តែមិនទាន់ដឹងថាប៉ុន្មានឆ្នាំទៀតទើបបានលេខ១នោះទេ។

មិនតែប៉ុណ្ណោះ សម្តេចក្រឡាហោម ក៏បានពន្យល់អំពីចំណាត់ថ្នាក់តរៀងគ្នាផងដែរ ដូចជាសម្រាប់ចំណាត់ថ្នាក់លេខ១ ជាប្រទេសដែលគ្មានអំពើជួញដូរមនុស្ស ចំណែកឯចំណាត់ថ្នាក់លេខ២ ជាប្រទេសដែលមានការជួញដូរមនុស្សតិចតួច នេះដោយសាររដ្ឋាភិបាលមានឆន្ទៈ ចំពោះចំណាត់ថ្នាក់លេខ៣ ជាប្រទេសដែលមានការជួញដូរមនុស្ស ហើយរដ្ឋាភិបាលគ្មានឆន្ទៈក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាប ។

អំពើជួញដូរមនុស្ស រួមទាំងការលក់ដូរមនុស្ស ការជួញដូរសេរីរាង្គមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទលើមនុស្ស បានធ្វើឲ្យមនុស្សគ្រប់ភេទ គ្រប់វ័យ តាំងពីទារក កុមារ យុវវ័យ និងមនុស្សចាស់រាប់លាននាក់ នៅស្ទើរតែគ្រប់ទីកន្លែងក្នុងពិភពលោក រងទុក្ខវេទនា បាត់បង់កិត្តិយស សេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស និងសេចក្តីសុខក្នុងគ្រួសារ ខូចខាតសុខភាព ផ្លូវកាយ ផ្លូវចិត្តផ្លូវភេទ រហូតដល់អាយុជីវិតរបស់មនុស្សរៀងរាល់ថ្ងៃ។ នេះជាសោកនាដកម្មសម្រាប់មនុស្សជាតិ ដែលបង្កដោយជនអគតិ និងឧក្រិដ្ឋកម្មទាំងឡាយដែលព្យាយាមរកគ្រប់វិធី ដើម្បីចំណេញផលប្រយោជន៍លើអ្នកដទៃ ទោះបីជាធ្វើឲ្យគេរងទុក្ខវេទនា ផ្លូវកាយ ផ្លូវចិត្ត និងអាយុជីវិតយ៉ាងណាក៏ដោយ នេះវាជាអំពើឃោរឃៅអមនុស្សធម៌ គួរឲ្យស្អប់ខ្ពើម។

រាជរដ្ឋាភិបាលមានគោលនយោបាយក្នុងការលើកកម្ពស់ ការគោរពសិទ្ធិមនុស្ស កិច្ចការពារប្រជាពលរដ្ឋពីការរំលោភបំពាន កេងប្រវ័ញ្ច និងអំពើជួញដូរមនុស្ស គ្រប់រូបភាព ហើយយើងទាំងអស់គ្នាប្តេជ្ញាចិត្តធ្វើសកម្មភាពបង្ការ ទប់ស្កាត់ តាមរយៈការបន្តផ្សព្វផ្សាយ អប់រំណែនាំតាមបែបសាសនាដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីឲ្យយល់ដឹងអំពីប្រភេទ និងផលប៉ះពាល់នៃបទល្មើសជួញដូរមនុស្ស និងនាំគ្នាលុបបំបាត់ទាសភាពសម័យទំនើបនេះ ឲ្យអស់ពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ យើងក៏មិនអត់អោនចំពោះជនណាដែលបង្កបញ្ហា សាងនូវបទឧក្រិដ្ឋបំផ្លាញមនុស្សជាតិ និងបំបែកបំបាក់សាមគ្គីភាព ភាពសុខដុមរមនាក្នុងសង្គម ព្រមទាំងបំផ្លាញវប្បធម៌ប្រពៃណី ដ៏ល្អផូរផង់របស់យើងដែលមានតាំងពីយូរលង់មកហើយ គឺចាំបាច់ត្រូវតែលើកកម្ពស់ការអនុវត្តច្បាប់ ដើម្បីផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ឲ្យសក្តិសមនឹងការប្រព្រឹត្ត និងដើម្បីឲ្យមានយុត្តិធម៌ ក្នុងសង្គម។

ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្តេចបានឧទ្ទិស បួងសួងដល់គុណបុណ្យព្រះរតនត្រ័យ បារមី វត្ថុស័ក្តិសិទ្ធិ ក្នុងលោក ព្រះអាឡា ព្រះយេស៊ូគ្រិស្ត ដែលតែងតែជួយទ្រទ្រង់ ថែរក្សាមនុស្សលោក សូមទទួលយកនូវការអធិដ្ឋានរបស់បរិស័ទនៃសាសនាទាំងអស់ ដែលមានឆន្ទៈដាច់ខាតប្រឆាំងអំពើជួញដូរ និងកេងប្រវ័ញ្ចគ្រប់រូបភាពលើមនុស្ស និងសូមបញ្ចប់ឲ្យបាន នូវទាសភាពសម័យទំនើបនេះដើម្បីសេចក្តីសុខរបស់ប្រជាជនកម្ពុជា និងមនុស្សជាតិទាំងឡាយតរៀងទៅ៕

បន្ទាប់មក លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានថ្លែងសាររួមក្នុងពិធីសូត្រធម៌ អធិដ្ឋានដែលមានចំនួន៩ចំនុច មានខ្លឹមសារដូចតទៅៈ

*១-អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ ជាអំពើបាបយ៉ាងធ្ងន់ធ្ងរ ត្រូវជៀសវាង*

*២-យើងទាំងអស់គ្នាប្រឆាំងដាច់ខាតចំពោះបទឧក្រិដ្ឋជួញដូរមនុស្ស និងបទឧក្រិដ្ឋដទៃទៀត*

*៣-សូមគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ជីវភាពកម្មករ កសិករ មន្ត្រីរាជការ ដើម្បីការបន្ថយការដោយប្រថុយប្រថាន*

*៤-យើងទាំងអស់គ្នា គ្រប់ភេទ គ្រប់វ័យ មិនមែនជាទំនិញសម្រាប់ឲ្យជនល្មើសជួញដូរ ឬកេងប្រវ័ញ្ចឡើយ*

*៥-យើងខ្ញុំគាំទ្រ និងជំរុញការផ្តន្ទាទោសជនល្មើស ដើម្បីផ្តល់យុត្តិធម៌ជូនជនរងគ្រោះ*

*៦-ប្តេជ្ញាពង្រីកការយល់ដឹង អំពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ទៅសហគមន៍យើង ដើម្បីបានរួចផុតភាពរងគ្រោះ*

*៧-យើងរួមគ្នាធ្វើអំពើល្អ ជួយថែទាំ និងមិនរើសអើងជនរងគ្រោះដែលមាននៅក្នុងសហគមន៍យើង*

*៨-មនុស្សទាំងឡាយ ទោះមានជំនឿសាសនា និងស្ថានភាពខុសគ្នាយ៉ាងណា ក៏នៅតែជាបងប្អូនយើង ដែលត្រូវផ្តល់យកចិត្តទុកដាក់ និងអាណិតស្រឡាញ់ដូចៗគ្នា*

*៩-សូមគាំទ្រយ៉ាងពេញទំហឹង នូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការក្នុងការលើកកម្ពស់ សុខដុមនីយកម្មសាសនានៅកម្ពុជា*

ជាចុងបញ្ចប់កម្មវិធី មានពិធីសូត្រធម៌បញ្ជូនសារតាមបែបព្រះពុទ្ធសាសនា ពិធីអធិដ្ឋានបញ្ជូនសារតាមបែបគ្រិស្តបរិស័ទកាតូលិក ពិធីអធិដ្ឋានបញ្ជូនសារតាមបែបគ្រិស្តបរិស័ទដំណឹងល្អ និងពិធីសូត្រធម៌បញ្ជូនសារតាមបែបឥស្លាមសាសនា។ បន្ទាប់មកមានពិធីធម្មយាត្រាដង្ហែសារដើរតាមផែននីមួយៗចេញមកខាងក្រៅរួមជាមួយការលើកផ្ទាំងសារ និងមានការសូត្រធម៌ជូនពរជ័យដល់គ្រប់ពុទ្ធបរិស័ទ និងសាសនិកគ្រប់និកាយ និងមានការបង្ហោះប៉េងប៉ោងដែលមានភ្ជាប់សារទៅជាមួយផងដែរ។

អង្គពិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប បានបញ្ចប់នៅវេលាម៉ោង១៨:៣០នាទីរសៀលថ្ងៃទី៣០ខែសីហា ឆ្នាំ២០១៨ ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រៃលែង ។

ថ្ងៃ..........ខែ..........ឆ្នាំ..........សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៨

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ត្រី.អ៊ឹម_សុខជា

បាទឃើញ 04/09/18

ជួ_ប៊ុនអេង

បានឃើញ និងសូមគោរពជូន

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ថ្ងៃ..........ខែ..........ឆ្នាំ..........សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៨

**អគ្គលេខាធិការរង**

ឧត្តមសេនីយ៍ទោ.អ៊ី_ម៉ារីកា